**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**
លេខ......០៤៥.........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- បានឃើញប្រកាសលេខ ០១៥ អ.ស.ហ.ប្រក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង
- យោងតាមការស្នើរបស់និយ័តករគណនេយ្យនិងសវនកម្ម

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង (**គ.ត.ស.អ.**) ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាននៃការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ **គ.ត.ស.អ.** ព្រមទាំងកិច្ចការទាំងឡាយពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង។

## ជំពូកទី២
## ការរៀបចំ និងការប្រព្រឹត្តទៅ

**ប្រការ៣ .-**

**គ.ត.ស.អ.** ត្រូវបានបង្កើតឡើង និងមានកំណត់សមាសភាព អាណត្តិ តួនាទីនិងភារកិច្ច តាមរយៈប្រកាសលេខ០១៥ អ.ស.ហ.ប្រ.ក. ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង។

ប្រធាន **គ.ត.ស.អ.** អាចស្នើសុំបន្ថែម ឬបន្ថយសមាសភាពសមាជិករបស់ **គ.ត.ស.អ.** ទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមការចាំបាច់។

**គ.ត.ស.អ.** មានលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាល និងបច្ចេកទេស ដែលសមាសភាពរបស់លេខាធិការដ្ឋានត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទី និងភារកិច្ច ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ស.អ.**។ សមាសភាពរបស់លេខាធិការដ្ឋាននេះត្រូវជ្រើសចេញពីមន្ត្រីនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និង/ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀតនៃនិយ័តករគណនេយ្យនិងសវនកម្ម។

**ប្រការ៤ .-**

លេខាធិការដ្ឋាននៃ **គ.ត.ស.អ.** មានភារកិច្ចដូចខាងក្រោម៖

- បំពេញតួនាទីជាសេនាធិការរដ្ឋបាល និងបច្ចេកទេសជូន **គ.ត.ស.អ.**
- សម្របសម្រួលការងារជាមួយសមាជិក សមាជិកា និងក្រុមការងារចំណុះ **គ.ត.ស.អ.**
- រៀបចំ និងសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងកិច្ចប្រជុំរបស់**គ.ត.ស.អ.** ព្រមទាំងរៀបចំកំណត់ហេតុ ឬរបាយការណ៍នៃកិច្ចប្រជុំ
- ប្រមូលចងក្រង និងរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផល ឬវឌ្ឍនភាពការងារប្រចាំឆមាស និងប្រចាំឆ្នាំ ឬតាមកាលកំណត់ផ្សេងទៀតក្នុងក្របខណ្ឌការងារត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាងជូន **គ.ត.ស.អ.**
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនពី **គ.ត.ស.អ.** និងប្រធាន **គ.ត.ស.អ.**។

**ប្រការ៥ .-**

**គ.ត.ស.អ.** ត្រូវប្រជុំសាមញ្ញយ៉ាងតិច២(ពីរ)ដង ក្នុងមួយឆ្នាំ ទៅតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ កិច្ចប្រជុំវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការសម្រេចរបស់ប្រធាន ឬតាមការស្នើសុំរបស់សមាជិកយ៉ាងតិច ២/៣ (ពីរភាគបី)។

អនុប្រធាន និងសមាជិកនៃ **គ.ត.ស.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ត.ស.អ.**។ លិខិតអញ្ជើញ របៀបវារៈ និងឯកសារពាក់ព័ន្ធត្រូវផ្ញើជូនប្រធាន អនុប្រធាន និងសមាជិក យ៉ាងហោចណាស់ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកិច្ចប្រជុំ វៀរលែងតែកិច្ចការបន្ទាន់។ ក្នុងករណីអវត្តមានប្រធាន **គ.ត.ស.អ.** ត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំប្រជុំជំនួស ដើម្បីធានានិរន្តរភាពនិងប្រក្រតីភាពនៃការអនុវត្តតួនាទីភារកិច្ចរបស់ **គ.ត.ស.អ.**។

កិច្ចប្រជុំរបស់ **គ.ត.ស.អ.** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្ដាលនៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ក្នុងករណីកិច្ចប្រជុំលើកទីមួយមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុខ្វះកូរ៉ុម ប្រធានអាចកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរបាន ក្នុងរយៈពេល១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកាលបរិច្ឆេទដែលបានកំណត់លើកទីមួយ។ កិច្ចប្រជុំលើកទី២នេះមិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែរបៀបវារៈដែលខកខានប្រជុំលើកទីមួយប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់ **គ.ត.ស.អ.** អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងបែកជាពីរស្មើគ្នា សំឡេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។

**ប្រការ៦ .-**

រាល់កិច្ចប្រជុំរបស់ **គ.ត.ស.អ.** ត្រូវមានកំណត់ហេតុ។

សេចក្តីសម្រេចរបស់ **គ.ត.ស.អ.** ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាកត់ត្រា។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃ **គ.ត.ស.អ.** ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំតាមរយៈឯកសាររឹង និង/ឬសារអេឡិចត្រូនិច។

**ប្រការ៧ .-**

លាភការរបស់ប្រធាន អនុប្រធាន និងសមាជិក **គ.ត.ស.អ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់អគ្គនាយកនៃ **ន.គ.ស.** និងជាប្រធាន **គ.ត.ស.អ.**។

**ប្រការ៨ .-**

**គ.ត.ស.អ.** ប្រើប្រាស់ត្រានិងធនធានហិរញ្ញវត្ថុរបស់ **ន.គ.ស.** ដើម្បីបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៣
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ៩ .-**

**គ.ត.ស.អ.** អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអន្តរជាតិ និងប្រភពស្របច្បាប់ផ្សេងៗ តាមនីតិវិធីស្របច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**គ.ត.ស.អ.** អាចស្នើសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលខាងលើ សម្រាប់ជាកម្មវត្ថុនៃការគ្រប់គ្រងកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង និងអភិវឌ្ឍស្ថាប័ន **ន.គ.ស.**។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពនៃក្រុមប្រឹក្សានៃ អ.ស.ហ. "ដើម្បីជូនជ្រាប"
- ដូចប្រការ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ